# ជំហានទី១

យើងព្រមសារភាពថាយើងគ្មានអំណាចចំពោះការផ្តាច់គ្រឿងស្រវឹងនោះបានឡើយ ហើយយើងក៏ដឹងថាយើង មិនអាចគ្រប់គ្រងឬចាត់ចែងជីវិតរស់នៅរបស់យើងបានទៀតឡើយ។

គ្មាននរណាម្នាក់ព្រមសារភាពថាខ្លួនរបស់គេបរាជ័យទាំងស្រុងនោះទេ។ បិត្តគំនិតនិងព្រលឹងរបស់យើងទាំងស្រុងមានប្រតិកម្មស្អប់ចំពោះការដែលថាយើងគ្មានអំណាចចំពោះការផ្តាច់ស្រានោះឡើយ។ យើងមិនចង់ស្តាប់ មិនចង់ឮពាក្យដែលថាយើងជាមនុស្សញៀនស្រាយ៉ាងងប់ងុលនោះឡើយ ប៉ុន្តែមានតែព្រះទេដែលអាចជួយយើងឲ្យបានស្រាកស្រាន្តនោះដែរ។

យើងបានបណ្តោយឲ្យស្រានាំយើងឲ្យជួបវិបត្តិផ្នែកហិរញ្ញវត្ថុ ផ្នែកអារម្មណ៍ និងការបង់ខាតខាងផ្នែកសីលធម៌។ ស្រានាំយើងក្លាយជាអ្នកជំពាក់លុយគេ ដោយព្រោះតែត្រូវការវាយកទៅទិញរបស់នោះមកបំពេញតម្រូវការរបស់យើង។ នៅពេលដែលយើងផឹក យើងត្រូវតែទទួលផលនៃការផឹកនោះ។ ការទទួលផលនៃការផឹកគ្រឿងស្រវឹងនោះគឺធ្វើឲ្យយើងអត់ការងារធ្វើ គ្រួសារបាក់បែក បាក់ទឹកចិត្ត មិត្តភក្តិ និងគ្រួសារគេឈប់មិនរាប់អាន។ (ដូចសុភាសិតខ្មែរ "ស្រាវាថ្លៃ បើប្រើវាល់ថ្ងៃនាំជនប្រុសស្រីទៅជាថោក") ។ ការប្រើសុរានាំឲ្យបង់ថ្លៃខ្ពស់ដើម្បីលោះខ្លួនយើងឲ្យរួច តែទោះជាយ៉ាងណាក៏ដោយយើងមិនអាចដោះខ្លួនរួចងាយឡើយ។ នៅពេលដែលយើងព្រមទទួលស្គាល់ថាយើងមិនយកឈ្នះវាបាននោះគ្រប់គ្រា គឺជាទ្វារច្រកចេញសម្រាប់យើងអាចដោះខ្លួនយើងឲ្យរួចបាន។

ប៉ុន្តែតាមរយៈការចូលរួមជាមួយនឹង អេអេ ពួកយើងនឹងចាប់យកទស្សនៈមួយទៀត ដែលទាក់ទងនឹងភាពអាម៉ាស និងភាពបរាជ័យរបស់យើង។ យើងចាប់ផ្តើមដឹងថាមានតែការដែលយើងបរាជ័យទាំងស្រុងប៉ុណ្ណោះដែលអាចនាំយើងឲ្យបោះជំហានដំបូងទៅរកសេរីភាពនៃការផ្តាច់ខ្លួនចេញពីភាពញៀនគ្រឿងស្រវឹងបាន។

ការព្រមទទួលសារភាពរបស់ពួកយើងថា យើងគ្មានអំណាចដើម្បីបញ្ឈប់ការផឹកគ្រឿងស្រវឹង វានឹងប្រែក្លាយទៅជាគ្រឹះដ៏រឹងមាំ ដែលនាំឲ្យយើងមានជីវិតថ្មីមួយ ដែលមានគោលបំណងច្បាស់លាស់។

យើងដឹងថាអ្នក**ញៀនស្រា** ដែលបានចូលរួមជាមួយអេអេ គេមិនអាចបានផ្លាស់ប្តូរបានទេ លុះត្រាតែពួកគេព្រមទទួលសារភាពថាពួកគេគ្មានអំណាចក្នុងការបញ្ឈប់ផឹកគ្រឿងស្រវឹងដោយខ្លួនឯង និងការគ្រប់គ្រងទៅលើខ្លួនឯង ហើយព្រមទទួលថាជីវិតរបស់ពួកគេត្រូវបានរលំរលាយ ព្រមទាំងទំនាក់ទំនងជាច្រើនទៀតបានបាត់បង់អស់ មិនស្រស់ផូរផង់ដូចមុនទៀតគ្មានញាតិមិត្តរាប់អានទៀតដែរ។ លើកលែងតែអ្នកញៀនគ្រឿងស្រវឹងព្រមទទួលស្គាល់សេចក្តីពិតទាំងនេះ បើអ្នកញៀនគ្រឿងស្រវឹងមិនព្រមទទួលសេចក្តីពិតទាំងនេះទេ គេមិនអាចឈប់ទទួលទានគ្រឿងស្រវឹងបានយូរនោះទេ។ អ្នកញៀនគ្រឿងស្រវឹងនឹងមិនអាចដំណើការទៅមុខបានទេ លុះត្រាតែព្រមទទួលជំហានទី១។ នេះដោយយោងតាមបទពិសោធន៍របស់អេអេ ដែលមានរយៈពេលមួយសតវត្សរ៍បានចែកចាយសេចក្តីពិតតាមរយៈបទពិសោធន៍របស់គេ។

គោលការណ៍ដែលយើងរកឃើញនោះគឺ មិនមានកម្លាំងអ្វីមួយមកផ្លាស់ប្តូរបានទេ លើកលែងតែការសារភាពពីបរាជ័យទាំងស្រុងរបស់យើង ទើបអាចយកឈ្នះការញៀននោះបាន។ ការសារភាពនេះវាជាមូលដ្ឋានគ្រឹះមួយនៃការរីកលូតលាស់របស់អេអេ អស់រយៈពេលជាច្រើនឆ្នាំ។

មុនដំបូងនៅពេលដែលគេបបួលយើងឲ្យយើងសារភាពថា យើងបរាជ័យគឺយើងភាគច្រើនតែងតែខឹង។ យើងគិតថាយើងគួរតែមានជំនឿជឿជាក់លើខ្លួនឯងតាមរយៈអេអេ ដើម្បីផ្តាច់ស្រាដោយខ្លួនឯងផ្ទាល់បាន។ នៅក្នុងអេអេ បានបង្រៀនមនុស្សថាជំនឿជឿជាក់លើខ្លួនឯងឥតមានប្រយោជន៍សម្រាប់យើងទេ វាគ្រាន់តែជាឧបសគ្គមួយដែលមករារាំងយើង នៅពេលដែលយើងព្យាយាមផ្តាច់គ្រឿងស្រវឹង។ អ្នកផ្តល់ឱវាទរបស់អេអេបានប្រាប់យើងថាការផឹកស្រាបានក្លាយទៅជាការញៀនមួយនៅក្នុងសតិអារម្មណ៍ ដែលតែងតែគិតអំពីវារហូតយើងមិនមានកម្លាំង ឆន្ទៈ សូម្បីតែ1%ដើម្បីយកឈ្នះលើការញៀនគ្រឿងស្រវឹងរបស់យើងបានឡើយ។ យើងដែលជាអ្នកញៀនគ្រឿងស្រវឹងនឹងទទួលបានផលវិបាកពីរ ទីមួយគឺ គំនិតមើលមមាយគិតអំពីតែការញៀនគ្រឿងស្រវឹង និងមួយទៀតគឺការញៀនរបស់រាងកាយ។ មានចំនួនតិចតួចបំផុតនៃអ្នកដែលញៀន ដែលពួកគេអាចចេញផុតពីការញៀននោះបានដោយអំណាចឆន្ទៈផ្ទាល់ខ្លួនរបស់គេ។ តាមស្ថិតិមានមនុស្សតិចបំផុតដែលមានឆន្ទៈ កម្លាំង និងអំណាចដែលអាចទាញខ្លួនរបស់គេមកវិញបានដោយខ្លួនឯងនោះ។

ចូរត្រឡប់មើលទៅប្រវត្តិរបស់អេអេ យើងឃើញថាសូម្បីតែអ្នកដែលញៀនស្រាដ៏ខ្លាំងជាងគេវាពិបាកណាស់ក្នុងការប្រឈមមុខទៅនឹងភាពលំបាកដ៏អស់សង្ឃឹមរបស់ពួកគេ ប៉ុន្តែមានមួយចំនួនតូចគេអាចទទួលស្គាល់ស្ថានភាព ដែលមិនមានសេចក្តីសង្ឃឹមទាល់តែសោះរបស់ពួកគេ។ នៅកាលណាគេចាប់ផ្តើមអនុវត្តគោលការណ៍របស់អេអេ គឺគេនឹងមានភាពល្អប្រសើរ វាប្រៀបដូចជាមនុស្សម្នាក់កំពុងលង់ក្នុងសមុទ្រ ហើយមានគេបោះពោងឲ្យស្រវ៉ាចាប់ដើម្បីជួយជីវិតឲ្យរួចផុតពីសេចក្តីស្លាប់។ គេជិតនឹងបានប្រសើរឡើងវិញពីការញៀនទៅហើយ។

នៅពេលដែលនៅពេលដែលសៀវភៅរបស់អេអេបានបោះពុម្ពជាលើកដំបូង គឺក្នុងគោលបំណងជួយដល់មនុស្សដែលទល់ច្រកជាទីបំផុត (ឧទាហរណ៍ អ្នកដែលបាត់បង់ក្រុមគ្រួសារ ការងារ ទ្រព្យសម្បត្តិ ហើយថែមទាំងមានជំងឺ)។ អ្នកញៀនគ្រឿងស្រវឹងជាច្រើនមិនទាន់មានភាពអស់សង្ឃឹម ឬបញ្ហាលំបាកណាមួយនោះទេ ដូច្នេះពួកគេមិនទាន់ស្វែងរកជំនួយពីអ្នកណាទេ ពីព្រោះពួកគេគិតថាគេអាចគ្រប់គ្រងជីវិតរបស់គេបាន។

អស់រយៈពេលជាច្រើនឆ្នាំ ស្ថានភាពនេះបានផ្លាស់ប្តូរ។ អ្នកញៀនគ្រឿងស្រវឹងដែលនៅមានសុខភាពល្អ អ្នកដែលនៅមានក្រុមគ្រួសារ និងមានការងារធ្វើនៅឡើយ គេបានចាប់ផ្តើមទទួលស្គាល់ការញៀនគ្រឿងស្រវឹងរបស់ពួកគេ។ អ្នកផឹកជាច្រើនអ្នកដែលមិនទាន់ញៀនគ្រឿងស្រវឹងខ្លាំង គេបានចាប់ផ្តើមមកដើរតាមអេអេ ហើយពួកគេចាប់ផ្តើមទទួលយកការជួយសង្គ្រោះ ដូច្នេះពួកគេបានគេចផុតពីស្ថានភាពដ៏យ៉ាប់យ៉ឺនទាំងនោះ គឺមិនដូចអ្នកដែលញៀនខ្លាំងដូចអេអេសម័យមុនទាំងនោះទេ។

មនុស្សដែលញៀនខ្លាំងដែលបានជួបបញ្ហាដ៏លំបាកទាំងនោះគឺជាសមាជិកដំបូងដែលអេអេ បានទទួលបទពិសោធន៍។ ប្រសិនបើជំហានទីមួយដែលយើងសារភាពថាយើងមិនអាចគ្រប់គ្រង និងរៀបចំជីវិតរបស់ខ្លួនឯងបានទេ តើមនុស្សដែលមិនទាន់ជួបបញ្ហាដ៏លំបាកទល់ច្រក គេគួរតែយកជំហាននេះទៅអនុវត្តយ៉ាងម៉េចកើតទៅ?

សមាជិកដំបូងរបស់អេអេ បានក្រឡេកមើលត្រឡប់ទៅអតីតកាលរបស់ពួកគេ ចំពោះបទពិសោធន៍នៃការផឹករបស់ពួកគេ គេឃើញថាជាច្រើនឆ្នាំនៃអតីតកាលនោះដែលពួកគេមិនអាចគ្រប់គ្រងខ្លួនឯងបាន។

ការផឹករបស់ពួកគេនៅពេលនោះគឺពិតជាការផឹកដ៏ច្រើនហួសហេតុ។ ការផឹកដ៏ងុបងុល វាប្រៀបដូចជាការរអិលធ្លាក់ចុះទៅក្នុងជ្រោះនៃសេចក្តីស្លាប់។ តែប្រសិនបើពួកគេបានគិតថា ពួកគេគ្រាន់តែជាអ្នកផឹកដ៏ច្រើនលើសលុបម្នាក់ តែមិនមែនជាអ្នកដែលញៀននោះទេ នោះយើងនឹងឲ្យដំបូន្មានទៅពួកគេថា "ពិតហើយប្រហែលជាអ្នកនិយាយត្រូវ អ្នកមិនមែនជាអ្នកដែលញៀននោះទេ" សូមអញ្ជើញប្អូនចេញទៅក្រៅ ហើយសាកល្បងផឹកម្តងទៀតមើល ហើយសូមព្យាយាមគ្រប់គ្រងការផឹកនោះ ហើយព្យាយាមគិតអំពីអ្វីដែលអេអេយើងបានប្រាប់អ្នកអំពីរោគញៀនគ្រឿងស្រវឹង ក្នុងប្រការនោះគឺមានន័យថាអេអេបានសាបគ្រាប់ពូជចូលទៅក្នុងគំនិតរបស់គេរួចជាស្រេចហើយ ដូច្នេះគេមិនអាចត្រលប់ទៅផឹកម្តងទៀតបានទេ កាលណាគេផឹកគេនឹងនឹកឃើញអំពីអេអេ វាដូចជាអេអេកំពុងដាស់តឿនគេអីចឹង ហើយពួកគេនឹងឆ្ងល់ថាតើគេធ្លាប់ជាមនុស្សញៀនគ្រឿងស្រវឹងមែនទេ។ ភាគច្រើនអ្នកទាំងនោះគេបានព្យាយាមដកពិសោធន៍នូវការគ្រប់គ្រងការផឹករបស់គេ គេបានត្រឡប់ទៅកាន់អេអេវិញមុនពេលដែលគេនឹងត្រូវបាត់បង់គ្រប់បែបយ៉ាង។ គេបានធ្លាក់ដល់បាត ប៉ុន្តែវាមិនធ្ងន់ធ្ងរដូចអ្នកខ្លះ ក្នុងចំណោមពួកយើងដែលគេកំពុងធ្វើដំណើរទៅកន្លែងដែលលំបាកជាទីបំផុតមួយ ដែលគ្រោះថ្នាក់ដូចជាការ រអិលធ្លាក់ចូលទៅក្នុងជ្រោះ បើពួកគេបានដឹងរួចជាស្រេចពីស្ថានភាពលំបាកទាំងនោះពួកគេនឹងត្រឡប់ថយក្រោយវិញ។

- ហេតុអ្វីបានជាអេអេ សួរថាអ្នកញៀនគ្រឿងស្រវឹងគួរតែបុកជញ្ជាំងជាមុនសិន? ពីព្រោះអេអេបានមើលឃើញថាមានមនុស្សតិចតួចណាស់ ដែលគេចង់អនុវត្តគោលការណ៍អេអេ លុះត្រាណាពេលដែលគេជួបបញ្ហាលំបាក ឬក៏គេទល់ច្រកដោះស្រាយមិនចេញ។

- នៅពេលដែលយើងចូលរួមជាមួយអេអេ យើងមិនអាចអនុវត្តជំហានទី២ រហូតដល់ទី១២ បានទេ លុះត្រាតែយើងចាប់យកជំហានទី១ជាមុនសិន។ ដោយសារជំហានទី២-១២ ទាមទារឲ្យយើងមានអាកប្បកិរិយា និងសកម្មភាពដែលមានភាពស្អាតស្អំ សុចរិត ស្មោះត្រង់។ មានន័យថា អ្នកដែលបានឆ្លងកាត់ជំហានទី១បាននោះលុះត្រាតែគេជាមនុស្សម្នាក់ដែលបានឆ្លងកាត់ការពិសោធន៍នៃភាពស្មោះត្រង់ និងភាពស្អាតស្អំរួចហើយ ពីព្រោះគេដឹងថាគេបានកុហកខ្លួនឯង និងអ្នកដទៃ។ អ្នកដែលកំពុងដែលផឹកមិនអាចឈានចូលទៅកាន់ជំហានទី២ដល់ទី១២របស់អេអេបានទេ ពីព្រោះជំហានទាំងនោះទាមទារឲ្យយើងមានភាពស្មោះត្រង់ សុចរិត តែបើយើងផឹកខ្លាំង មានន័យថាយើងកំពុងតែកុហកខ្លួនឯង និងអ្នកដទៃ។

- តើអ្នកចង់មានភាពស្មោះត្រង់ចំពោះខ្លួនឯងទេ? តើអ្នកណាចង់សារភាពកំហុសរបស់ខ្លួនចំពោះអ្នកដទៃ ហើយអ្នកនឹងធ្វើការសងគេវិញចំពោះអំពើមិនល្អនោះទេ? តើមានអ្នកណាខ្វល់ពីព្រះដែរឬទេ? សូមធ្វើការសញ្ជឹងគិតដោយខ្លួនឯង ហើយធ្វើការអធិស្ឋាន តើអ្នកណាចង់ថ្វាយពេលវេលា និងកំលាំងរបស់ខ្លួនដោយដើរតាមអេអេដោយនាំយកការល្អទាំងនោះពីអេអេ ទៅជួយអ្នកដែលរងគ្រោះ? អ្នកញៀនគ្រឿងស្រវឹង គេជាមនុស្សអាត្មានិយម គេមិនដែលខ្វល់ពីភាពស្មោះត្រង់ មិនខ្វល់ពីអ្នកដទៃ មិនស្គាល់អំពើល្អ អាក្រក់នោះទេ គេមិនខ្វល់ពីព្រះ គឺគេខ្វល់តែខ្លួនរបស់គេតែប៉ុណ្ណោះ។
- អ្នកញៀនគ្រឿងស្រវឹងកាលណាគេធ្លាក់ក្នុងសភាពយ៉ាប់យឺនខ្លាំង គឺវាប្រៀបបីដូចជាមនុស្សម្នាក់កំពុងតែលង់ទឹក គឺឃើញអ្វីក៏ស្រាវ៉ាតោងដែរគឺដើម្បីរស់ ដូចនេះកាលណាអ្នកញៀនគ្រឿងស្រវឹងទាំងនោះចង់មានជីវិតរស់នៅគេនឹងចាប់យកអេអេ ហើយកាលណាគេបានឆ្លងកាត់ជំហានទី១របស់អេអេ វាប្រៀបដូចជាគេត្រូវបានជួយសង្គ្រោះជីវិតគេឲ្យផុតពីសេចក្តីស្លាប់។